ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ: ០១២ ឧ.រ.ថ.-ន.នម-សរចណាន.

# សារាចរណែនាំ
## ស្តីពី
## ការហាមឃាត់តម្លើងបន្ថែម និងប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច ឬកម្មវិធី Software ដែលមានគោលបញ្ជាកំណត់បរិមាណផ្គត់ផ្គង់ ចែកចាយប្រេងឥន្ធនៈ

យោង :
- ព្រះរាជក្រមលេខៈ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- អនុក្រឹត្យលេខៈ ១៨៣ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សេចក្តីជូនដំណឹង ស្តីពី ការអនុវត្តន៍ច្បាប់មាត្រាសាស្ត្រកម្ពុជា លេខៈ ១៣២៤ ឧរថ.ម.ម.ជ. សជណ. ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១
- ពិនិត្យតាមសំណូមពរការងារចាំបាច់លើការគ្រប់គ្រងវិស័យមាត្រាសាស្ត្រ។

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ពិនិត្យឃើញថាបច្ចុប្បន្ននេះ រូបវន្តបុគ្គល ឬនីតិបុគ្គលមួយចំនួនបានប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្របែងចែកប្រេង (Fuel Dispenser) ក្នុងសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម ផ្គត់ផ្គង់ នៅតាមស្ថានីយ៍ចែកចាយប្រេងឥន្ធនៈ ដោយតម្លើងភ្ជាប់បន្ថែមនូវ ប្រព័ន្ធឧបករណ៍អគ្គិសនី ឬ ឧបករណ៍អេឡិចត្រូនិចដែលមានគោលបញ្ជាសម្រាប់កំណត់រង្វាស់រង្វាល់បរិមាណប្រេងឥន្ធនៈក្នុងការផ្គត់ផ្គង់ ចែកចាយ ដោយគ្មានការអនុញ្ញាត ពីសមត្ថកិច្ចគ្រប់គ្រងផ្នែកមាត្រាសាស្ត្រ និងផ្ទុយនឹងខ្លឹមសារក្នុងមាត្រា២៧ នៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជាទាំងស្រុង មិនតែប៉ុណ្ណោះឧបករណ៍អេឡិចត្រូនិចនេះ ជាមូលហេតុបង្កឱ្យមានការកេងបន្លំបរិមាណប្រេងឥន្ធនៈ ក្នុងការផ្គត់ផ្គង់ ចែកចាយ ដល់អតិថិជនបានគ្រប់ពេល និង យ៉ាងងាយស្រួលបំផុត។

ដើម្បីធានានិរន្តភាពនៃការគ្រប់គ្រងផ្នែកមាត្រាសាស្ត្រ និងការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រដូចមានចែងក្នុងជំពូកទី៦ នៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា ឲ្យបានត្រឹមត្រូវ និងវិធានការទប់ស្កាត់ការកេងបន្លំបរិមាណ **ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** សូមធ្វើការណែនាំដល់គ្រប់ រូបវន្តបុគ្គល និងនីតិបុគ្គល ដែលធ្វើសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម ផ្គត់ផ្គង់ ចែកចាយប្រេងឥន្ធនៈ ឬ ផ្តល់សេវាកម្មជួសជុល ឬ តម្លើងឧបករណ៍មាត្រាសាស្ត្របែងចែកប្រេងឥន្ធនៈនៅតាមស្ថានីយ៍ប្រេងឥន្ធនៈដែលបានកំពុង ឬ បម្រុងតម្លើងភ្ជាប់បន្ថែមនូវប្រព័ន្ធឧបករណ៍អគ្គិសនី ឬអេឡិចត្រូនិច ដែលមានគោលបញ្ជាកំណត់

បរិមាណប្រេងឥន្ធនៈក្នុងប្រព័ន្ធម៉ាស៊ីនផ្គត់ផ្គង់ចែកចាយប្រេងឥន្ធនៈដែលមានស្រាប់ត្រូវតែបញ្ឈប់ និង ហាមដាច់ខាតក្នុងការប្រើប្រាស់ ឬ ការតម្លើងបន្ថែមឧបករណ៍អគ្គិសនី ឬ អេឡិចត្រូនិចទាំងនោះ ។

ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនគោរពអនុវត្តតាមចរាចរណែនាំនេះ ក្រសួងនឹងចាត់វិធាន ការព្រមាន ឬពិន័យអន្តរការណ៍ ដូចមានចែងក្នុងជំពូកទី១០ "ទោសប្បញ្ញត្តិ" នៃច្បាប់ស្តីពីមាត្រាសាស្ត្រ កម្ពុជា។

ទទួលបានសារាចរណែនាំនេះ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ គ្រប់អគ្គនាយកដ្ឋាន វិទ្យាស្ថាន ស្តង់ដារកម្ពុជា នាយកខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ រូបវន្តបុគ្គល និង នីតិបុគ្គល ដែលធ្វើសកម្មភាពប្រើប្រាស់ ជួសជុល ឬ តម្លើងឧបករណ៍មាត្រាសាស្ត្រខាងលើត្រូវគោរពអនុវត្តប្រកប ដោយស្មារតីទទួលខុសត្រូវ និងប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១២

**រដ្ឋមន្ត្រី**

**ស៊ុយ សែម**

<u>**ចំលងជូន:**</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា
- គ្រប់ក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធ
- គ្រប់អគ្គនាយកដ្ឋាន-នាយកដ្ឋានក្រោមឱវាទក្រសួង ឧរថ
  "ដើម្បីជូនជ្រាប"
- គ្រប់សាលារាជធានី-ខេត្ត
- មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានី-ខេត្ត
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ